**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** ១៩៧ **ក.ប**/ប្រ.ក

# ប្រកាស

## ស្តីពី

## ការបង្កើតគណៈកម្មការពង្រឹងគុណភាព និងប្រសិទ្ធភាពការងារអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

២០១៣

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## <u>សម្រេច</u>

**ប្រការ ១.-** ត្រូវបានបង្កើតគណៈកម្មការពង្រឹងគុណភាព និងប្រសិទ្ធភាពការងារអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដើម្បីកែលម្អ និងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពការងាររបស់អង្គភាព/គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

**ប្រការ ២.-** គណៈកម្មការពង្រឹងគុណភាព និងប្រសិទ្ធភាពការងារអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១- ឯកឧត្តម ពេជ សោភ័ន | រដ្ឋលេខាធិការ | ប្រធាន |
| ២- ឯកឧត្តម ប៉ុក ប៉ាន់ | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣- ឯកឧត្តម រ័ត្ន ប៊ុនឡា | ទីប្រឹក្សាអមក្រសួង | អនុប្រធាន |
| ៤- ឯកឧត្តម ហេង សួរ | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ៥- ឯកឧត្តម ប៊ុន ភារិន | នាយកវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា | សមាជិក |

| | | |
|---|---|---|
| ៦- លោក យ៉ោក សុទ្ធី | នាយកវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស | សមាជិក |
| ៧- លោក ហាំង តុលា | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ៨- លោកស្រី មៅ ធីតា | អនុប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |
| ៩- លោក ឆាយ សុភា | អនុប្រធានការិយាល័យ ន.គ.ក.អ.ប.វ | សមាជិក |
| ១០- លោក ឡាក់ ឡុង | មន្ត្រី ន.គ.ក.អ.ប.វ | សមាជិក |

**ប្រការ ៣.-** គណៈកម្មការពង្រឹងគុណភាពនិងប្រសិទ្ធភាពការងារអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈមានតួនាទី និងភារកិច្ច ត្រួតពិនិត្យ វាយតម្លៃ និងផ្តល់យោបល់កែលម្អគុណភាព និងប្រសិទ្ធិភាពការងារគ្រប់គ្រង និងការអនុវត្តការងាររបស់អង្គភាព/គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ។

**ប្រការ ៤.-** នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងអង្គភាពពាក់ព័ន្ធ ព្រមទាំងឯកឧត្តម មន្ត្រីរាជការ ដូចមានក្នុងប្រការ២ខាងលើ ត្រូវអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១២

**រដ្ឋមន្ត្រី**

**វង សុត**

**<u>ចម្លងជូន៖</u>**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យលោកជំទាវឧបនាយករដ្ឋមន្ត្រីប្រចាំការ
-គណៈកម្មាធិការជាតិបណ្តុះបណ្តាល
"ដើម្បីជូនជ្រាប"
-មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត
-គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
"ដើម្បីជ្រាប"
-ដូចប្រការ៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ